00942141

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 07 / 2013
ម៉ោង (Time/Heure): 14:15 pm
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé ...: Buythi ...

E297

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈ- អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២ កាលបរិច្ឆេទៈ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៣

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង; មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការជូនដំណឹងស្តីពីឯកសារច្បាប់ដើមនៅក្នុងសំណុំរឿង

១. អង្គជំនុំជម្រះសូមរំឮកថាក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោក Stephen Heder លោកត្រូវបានគេសួរថា តើលោកមានរក្សាទុកទស្សនាវដ្តីទង់បដិវត្តច្បាប់ដើមដែរឬទេ។ លោក Heder បានឆ្លើយតបថា គាត់បានផ្តល់ឯកសារច្បាប់ដើមជូនដល់អង្គជំនុំជម្រះសាលាដំបូងរួចហើយ នៅពេលដែលអង្គជំនុំជម្រះបានស្នើសុំពីគាត់ (ប្រតិចារិកថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (ទំព័រ ២៨-២៩ អង់គ្លេស))។

២. ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ថា មានឯកសារច្បាប់ដើមចំនួនពីរ ដែលបានផ្តល់ជូនដោយលោក Heder ហើយត្រូវបានរក្សាទុកនៅអង្គភាពបណ្ណសារ ដែលឯកសារទាំងនោះរួមមាន ឯកសារ E169/4/1.1.1ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត (លេខ ៧ ខែកក្កដា ឆ្នាំ ១៩៧៥) និងឯកសារ E169/4/1.1.2 ទស្សនាវដ្តីទង់បដិវត្ត (លេខពិសេស ខែធ្នូ-មករា ឆ្នាំ ១៩៧៥-១៩៧៦)។

00942142

៣. ភាគី និងជនជាប់ចោទអាចធ្វើការពិនិត្យមើលឯកសារទាំងនោះបាន ដោយគ្រាន់តែធ្វើការសម្របសម្រួលជាមួយអង្គភាពបណ្ណសារ និងផ្នែកគ្រប់គ្រងតុលាការ។